Khmer




# សុវត្ថិភាពអគ្គិភ័យសម្រាប់មនុស្សចាស់ និងអ្នកមានពិការភាព

មនុស្សចាស់និងអ្នកមានពិការភាពប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំងនឹងការរងរបួស ឬការបាត់បង់ជីវិតដោយសារអគ្គិភ័យនៅផ្ទះរបស់ខ្លួន។ ជាធម្មតាបញ្ហានេះកើតឡើងនៅពេលដែលពិការភាព ឬជំងឺបង្កឲ្យមានផលប៉ះពាល់ដល់សមត្ថភាពរបស់បុគ្គលនីមួយៗ។ សូមពិចារណានូវស្ថានការណ៍របស់លោកអ្នក។ តើភាពចុះអន់ថយនៃសមត្ថភាពស្តាប់ ឬមើលឃើញមានន័យថា លោកអ្នកកាន់តែមានភាពយឺតយ៉ាវក្នុងការដឹងថា មានអគ្គិភ័យ ឬទេ? តើសមត្ថភាពធ្វើចលនាកាន់តែទន់ខ្សោយ មានផលប៉ះពាល់ដល់របៀបដែលលោកអ្នកត្រូវរត់ចេញពីអគ្គិភ័យនៅក្នុងផ្ទះដោយសុវត្ថិភាពឬទេ? ព័ត៌មាននៅក្នុងប័ណ្ណព័ត៌មាននេះព្រមជាមួយនឹងកូនសៀវភៅសុវត្ថិភាពអគ្គិភ័យនៅគេហដ្ឋាន ត្រូវបានរៀបចំឡើង ដើម្បីជួយលោកអ្នកក្នុងការកាត់បន្ថយការប្រឈមមុខនឹងគ្រោះថ្នាក់របស់លោកអ្នក ដែលបណ្តាលដោយអគ្គិភ័យ។

## ការព្រមានឱ្យដឹងមុនពេលគ្រោះថ្នាក់កើតឡើង

ការបាត់បង់ជីវិតដោយសារអគ្គិភ័យដែលពាក់ព័ន្ធនឹងមនុស្សចាស់ និងអ្នកមានពិការភាព កើតមានកាន់តែញឹកញាប់នៅតាមផ្ទះដែលមានឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង (smoke alarm) មិនដំណើរការ ឬឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យ ឬផ្សែង ដែលដាក់មិនត្រូវកន្លែង។ ការព្រមានឲ្យដឹងមុនពេលគ្រោះថ្នាក់អគ្គិភ័យកើតឡើង គឺជាការស្លាប់រស់សម្រាប់ជនរាល់រូប។ វាជាការសំខាន់ក្រៃលែងសម្រាប់អ្នកដែលមានពិការភាព។

- **ត្រូវមានឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង ច្រើនជាងមួយ**
  ការមានឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែងច្រើនជាងមួយគ្រឿង បង្កើនការព្រមានមុនពេលគ្រោះថ្នាក់អគ្គិភ័យកើតឡើងដល់លោកអ្នក។ សូមគិតអំពីលោកអ្នក និងផ្ទះលោកអ្នក។ តើលោកអ្នកបិទទ្វារនៅតាមកន្លែងទាំងឡាយនៃផ្ទះលោកអ្នកឬទេ? តើឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង ស្ថិតនៅកន្លែងមួយណា? បើលោកអ្នកពិសាបារី តើលោកអ្នកមានឧបករណ៍បញ្ចេញសំឡេងនេះ នៅក្នុងបន្ទប់ទាំងអស់ដែលលោកអ្នកពិសាបារីឬទេ? តើជួនកាល លោកអ្នកទទួលផលប៉ះពាល់ដោយសារថ្នាំពេទ្យ ឬស្រាឬទេ? តើឧបករណ៍បញ្ចេញសំឡេងមួយគ្រឿងនោះដែលស្ថិតនៅឯចុងម្ខាងទៀតនៃផ្ទះលោកអ្នក នឹងដាស់លោកអ្នកឲ្យភ្ញាក់ពីដំណេក ឬព្រមានលោកអ្នកឲ្យដឹងឬទេ?

- **ឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង ដែលតភ្ជាប់គ្នា**
  គេអាចតភ្ជាប់ជាមួយគ្នានូវបណ្តាឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យ ឬផ្សែងតាមរយៈប្រព័ន្ធវិទ្យុសញ្ញាគ្មានខ្សែ ឬការតខ្សែដ៏សាមញ្ញនៅខាងក្នុងដំបូលផ្ទះ។ នេះមានន័យថា បើឧបករណ៍បញ្ចេញសំឡេងមួយណាបន្លឺសំឡេងនៅឯបន្ទប់មួយក្នុងផ្ទះលោកអ្នក ឧបករណ៍បញ្ចេញសំឡេងទាំងអស់ដែលតភ្ជាប់គ្នានៅក្នុងផ្ទះលោកអ្នកក៏នឹងបន្លឺសំឡេងព្រមគ្នាដែរ។

- **ឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង សម្រាប់អ្នកថ្លង់ និងអ្នកលំបាកស្តាប់**
  ឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែងសម្រាប់អ្នកថ្លង់ និងអ្នកលំបាកស្តាប់ ធ្វើដំណើរការព្រមគ្នានឹងអំពូលភ្លើងឆេះភ្លឹបភ្លែត និងទ្រនាប់គ្រែដែលញ័ររញ្ជួយ។ លោកអ្នកអាចមានសិទ្ធិទទួលការជួយចេញថ្លៃពីរដ្ឋាភិបាល។ បើលោកអ្នកជាអ្នកជួលផ្ទះរដ្ឋ លោកអ្នកគួរទាក់ទងការិយាល័យទីលំនៅក្នុងតំបន់របស់លោកអ្នក ដើម្បីទទួលព័ត៌មានបន្ថែម។

- **ឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង ដែលតភ្ជាប់នឹងឧបករណ៍បញ្ចេញសំឡេងព្រមានផ្ទាល់ខ្លួន**
  ឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែង ដែលតភ្ជាប់ទៅនឹងឧបករណ៍បញ្ចេញសំឡេងព្រមានផ្ទាល់ខ្លួនមានន័យថា បើឧបករណ៍បញ្ចេញសំឡេងពេលមានភ្លើងឆេះ ឬផ្សែងកើតឡើងបន្លឺសំឡេងឲ្យដឹងសញ្ញាព្រមានមួយនឹងបញ្ជូនទៅកាន់ក្រុមហ៊ុនតាមពិនិត្យការព្រមានផ្ទាល់ខ្លួន។ នៅគ្រាសព្វថ្ងៃនេះ វិធីដូចនេះពុំមានផ្តល់ជូនតាមរយៈកម្មវិធីផ្តល់ការព្រមានផ្ទាល់ខ្លួនដែលជួយចេញថ្លៃដោយរដ្ឋាភិបាលឡើយ។

- **ការធ្វើតេស្ត**
  ជាការស្លាប់រស់ដែលត្រូវធ្វើតេស្តឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សែងរបស់លោកអ្នកជារៀងរាល់ខែ។ សុំឲ្យសមាជិកគ្រួសារ មិត្តភក្តិ ឬអ្នកជិតខាង បង្ហាញលោកអ្នកនូវរបៀបធ្វើតេស្តនេះ ឬស្វែងរកជំនួយពីអ្នកទាំងនោះដើម្បីធ្វើតេស្តឲ្យលោកអ្នក។

## ការឆ្លើយតបទៅនឹងអគ្គិភ័យ

កងពន្លត់អគ្គិភ័យ MFB ស្នើសុំឲ្យអ្នកមានសមត្ថភាពអន់ខ្សោយ ចាកចេញពីផ្ទះជាជាងការខិតខំពន្លត់អគ្គិភ័យ។ ផែនការរត់ចេញពីផ្ទះនឹងធានាថា លោកអ្នកអាចរត់ចេញដោយសុវត្ថិភាព នៅក្នុងពេលមានគ្រាអាសន្នណាមួយនៅគ្រប់ពេលទាំងអស់ ទោះជានៅពេលថ្ងៃឬពេលយប់ក៏ដោយ។ សូមហាត់អនុវត្តផែនការរត់ចេញនេះជាមួយអ្នកថែទាំគ្រួសារ, មិត្តភក្តិ ឬអ្នកជិតខាងដើម្បីឲ្យអ្នកទាំងនោះអាចជួយលោកអ្នកក្នុងការរកមើលដឹងការកែលំអណាមួយ។ ធ្វើឲ្យប្រាកដក្នុងការ៖

- ដាក់ទីតាំងបន្ទប់ដំណេកលោកអ្នកឲ្យនៅក្បែរផ្លូវច្រកចេញ,
- រក្សាបន្ទប់ដំណេកលោកអ្នកកុំឲ្យមានអីវ៉ាន់រាយប៉ាយ ដោយឲ្យមានផ្លូវចេញចូលដ៏ស្រឡះនៅជុំវិញគ្រែ និងទ្វារបន្ទប់,
- ទុកដាក់គ្រឿងឧបករណ៍ជំនួយចលនានៅកន្លែងងាយចាប់យកបាន នៅក្នុងបន្ទប់ដំណេកនៅពេលយប់,

- ពិចារណាក្នុងការចំហទ្វារខាងក្នុងទាំងអស់នៅពេលយប់ សម្រាប់ការរត់គេចងាយស្រួល,
- បើលោកអ្នកមានឧបករណ៍ផ្តល់ការព្រមានផ្ទាល់ខ្លួន សូមពាក់ឧបករណ៍នេះនៅពេលចូលដំណេក,
- នៅពេលដែលលោកអ្នកនៅផ្ទះ សូមដាក់កូនសោនៅក្នុងរន្ធសោ deadlock នៃទ្វារផ្ទះ ឬទ្វារដែកសន្តិសុខ ហើយកុំចាក់សោ deadlock នៃទ្វារផ្ទះ ឲ្យសោះ នៅពេលដែលលោកអ្នកនៅផ្ទះ,
- បន្ទាបខ្លួនឲ្យបានទាបទៅតាមលទ្ធភាពដែលលោកអ្នកអាចធ្វើបាន ដើម្បីគេចពីផ្សែងនៅពេលរត់ចេញពីផ្ទះ,
- រត់ចេញពីផ្ទះ និងកុំវិលទៅក្នុងផ្ទះវិញ,
- ទូរស័ព្ទទៅលេខ 000 ឬសុំឲ្យអ្នកជិតខាងទូរស័ព្ទទៅលេខនេះជួសលោកអ្នក។

បើលោកអ្នកមិនអាចរត់ចេញពីផ្ទះលោកអ្នកដោយគ្មានជំនួយទេនោះ លោកអ្នកគួរ៖

- ដាក់ទូរស័ព្ទមួយនៅក្បែរគ្រែដំណេកលោកអ្នក ហើយរៀបចំកម្មវិធីទូរស័ព្ទទុកជាមុនសម្រាប់ការចុចលេខសូន្យបីដង (000),
- ចុចទូរស័ព្ទលេខសូន្យបីដង (000), រង់ចាំការីទូរស័ព្ទ ហើយនិយាយថា FIRE (ហ្វៃអើ - អគ្គិភ័យ) រួចរង់ចាំឲ្យគេតភ្ជាប់ ហើយប្រាប់ថា លោកអ្នកមានអគ្គិភ័យ និងត្រូវការជំនួយរត់ចេញពីផ្ទះ,
- កុំដាក់ទូរស័ព្ទចុះ ដើម្បីឲ្យលោកអ្នកអាចប្រាប់គេនូវទីកន្លែងដែលគេអាចរកលោកអ្នកឃើញ,
- បន្ទាបខ្លួនឲ្យបានទាបតាមលទ្ធភាពដែលលោកអ្នកអាចធ្វើបាន ហើយគេចចេញពីផ្សែង និងកម្តៅ,
- បើលោកអ្នកអាច សូមបិទទ្វារបន្ទប់ដែលលោកអ្នកនៅខាងក្នុង ហើយដាក់កន្សែងពោះគោ, ពូកដំណេក និង/ឬខោអាវ នៅខាងក្រោមទ្វារ ដើម្បីកាត់បន្ថយផ្សែងកុំឲ្យចូលមកក្នុងបន្ទប់។

# ឱវាទផ្សេងទៀត

- ធ្វើឲ្យប្រាកដថា គេអាចមើលឃើញលេខផ្ទះលោកអ្នកយ៉ាងច្បាស់ពីដងផ្លូវ ដើម្បីឲ្យសេវាគ្រាអាសន្នអាចរកឃើញផ្ទះលោកអ្នកយ៉ាងងាយស្រួល។
- បើលោកអ្នកមានការលំបាកក្នុងការធ្វើចលនានៅក្នុងផ្ទះលោកអ្នកជារៀងរាល់ថ្ងៃ ហេតុការណ៍នេះអាចមានផលប៉ះពាល់ដល់ល្បឿននៃការដែលលោកអ្នកអាចរត់ចេញដោយសុវត្ថិភាព នៅក្នុងពេលមានគ្រាអាសន្ន។ សូមពិចារណាឲ្យមានការវាយតម្លៃដោយអ្នកព្យាបាលដោយចលនា និង/ឬ អ្នកព្យាបាលពាក់ព័ន្ធនឹងការងារ ដើម្បីទទួលឱវាទនិងព័ត៌មាន ដើម្បីបង្កើនឲ្យខ្លាំងបំផុតនូវឯករាជ្យភាពនិងសុវត្ថិភាពរបស់លោកអ្នក។
- បើលោកអ្នកកំពុងមានការលំបាកក្នុងការចាត់ចែងកិច្ចការទាំងឡាយ ដូចជាការចម្អិនអាហារដោយសុវត្ថិភាព សូមពិចារណាលើការទាក់ទងសាលាក្រុងរបស់លោកអ្នក ឬស្ថាប័នឯកជនដើម្បីសុំជំនួយ និង/ឬ សុំឲ្យយកអាហារទៅដល់ផ្ទះលោកអ្នក។
- ការប្រមូលសន្សំទុកអីវ៉ាន់ច្រើនឥតប្រយោជន៍ដែលទប់ចិត្តមិនបាន បង្កើនគ្រោះថ្នាក់នៃអគ្គិភ័យ និងការមិនអាចរត់ចេញពីផ្ទះបាន, សូមថែរក្សាផ្ទះលោកអ្នកកុំឲ្យមានអីវ៉ាន់រាយប៉ាយនៅតាមច្រកដើរក្នុងផ្ទះ និងក្បែរទ្វារចេញចូល។
- បើលោកអ្នកប្រើអុកស៊ីហ្សែនជាជំនួយព្យាបាល សូមអនុវត្តតាមឱវាទសុវត្ថិភាពដែលផ្តល់ដោយក្រុមហ៊ុនផ្គត់ផ្គង់ជានិច្ច។ ការមិនបានធ្វើយ៉ាងនេះ នឹងបង្កើនលទ្ធភាពនៃអគ្គិភ័យ និងសម្ពាធឧស្ម័នកាន់តែខ្លាំងឡើង។

ដើម្បីទទួលព័ត៌មានបន្ថែមអំពី

- សេវាព្យាបាលដែលពាក់ព័ន្ធនឹងការងារ/ការព្យាបាលដោយចលនា/ឧបករណ៍ព្រមានផ្ទាល់ខ្លួន ដែលឧបត្ថម្ភប្រាក់ដោយរដ្ឋាភិបាល សូមទាក់ទងមណ្ឌលសុខភាពសហគមន៍ក្នុងតំបន់លោកអ្នក

- ការជួយចេញថ្លៃឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សេង សម្រាប់អ្នកថ្លង់ និង អ្នកលំបាកស្តាប់ សូមទាក់ទង VicDeaf 9473 1111 TTY 9473 1199
  info@vicdeaf.com.au

- ជំនួយដល់ការរស់នៅ សូមទាក់ទង
  Yooralla Independent Living Centre 9666 4500
  yooralla@yooralla.com.au

- សេវានិងសម្ភារៈសម្រាប់អ្នកពិការភ្នែក ឬអ្នកលំបាកមើលឃើញ សូមទាក់ទង
  Vision Australia 1300 84 74 66,
  info@visionaustralia.org.au

- ការរស់នៅដោយមានជំងឺភ្លេចភ្លាំងវង្វេងវង្វាន់ម្យ៉ាងហៅថា dementia សូមទាក់ទង
  Alzheimer’s Australia Vic 9815 7800 alz@alzvic.asn.au

- បទបង្ហាញអំពីសុវត្ថិភាពអគ្គិភ័យសម្រាប់មនុស្សចាស់, ឧបករណ៍បញ្ចេញសំឡេងនៅពេលមានអគ្គិភ័យឬផ្សេង ឬការប្រមូលសន្សំទុកអីវ៉ាន់ និងគ្រោះថ្នាក់អគ្គិភ័យ, សូមទាក់ទង MFB Community Resilience – (03) 9665 4464 – commres@mfb.vic.gov.au

**Metropolitan Fire Brigade (MFB)**  **www.mfb.vic.gov.au**

© Metropolitan Fire & Emergency Services Board – P449I

V1 – May 2012